

**ការសំណេះសំណាល ជា មនោគតិ**

**អត្ថបទ នេះ ធ្លាប់បាន ចុះផ្សាយ តែ យក មក ពិនិត្យ និង កែសំរួល ឡើងវិញ ព្រោះ អ្វី ដែល ធ្លាប់ មាន កើត ឡើង នៅ ឆ្នាំ ២០១៣ នឹង មាន កើត ឡើង ម្តង ទៀត នៅ ឆ្នាំ ២០១៧-២០១៨។**

## បញ្ហា ការបោះឆ្នោត

សុខ និង សៅ ជា ក្លើ នឹងគ្នា ចូលចិត្ត ធ្វើ ការសំណេះសំណាល ជា មួយគ្នា អំពីទស្សនះនយោបាយជាតិ ដើម្បី ស្វែង រក សេចក្តី ពិត។ អ្នក ទាំង ពីរ តែងតែ ណាត់ ជួបគ្នា ជា មួយ មិត្ត សម្លាញ់ ច្រើនទៀត នាំ គ្នា ធ្វើ ការវែកញែក អំពី ព្រឹត្តិការណ៍ ដែល មាន កើត ឡើង ក្នុង ស្រុកខ្មែរ បច្ចុប្បន្ន។

សុខ ជា មតិភាណី[1] មាន ប្រាជ្ញា ជា អ្នកប្រាជ្ញ មាន ចំណេះ ជា បញ្ញវន្ត មាន គំនិត ប្រកប ដោយ គតិបណ្ឌិត និយាយ ពេល ណា នាំ ឲ មនុស្សម្នា ចង់ ស្តាប់ណាស់ ឯ ចំណែក សៅ ជា ជន សមញ្ញ មាន ប្រាជ្ញា ជា រាស្ត្រ មាន ចំណេះ ជា ថី មាន គំនិត ជា អ្នកជា។ បដិវាទ នេះឯង ដែល នាំ ឲ មិត្រ ចូលរួម ជជែក ក្នុង ការសំណេះ សំណាល ចូលចិត្ត ស្តាប់ នូវ វិចារវិទ្យា[2] របស់ សុខ និង សៅ។

---

[1] មតិភាណី ; homme éloquent pissement។
[2] វិចារវិទ្យា ; Dialectique។

នៅ ថ្ងៃ នេះ ក្មេី ទាំងនោះ នាំ គ្នា ជួបជុំគ្នា សំណេះ សំណាល អំពី រឿង ផ្សេងៗ នៃ ជីវិត ដូច សព្វដង។

តែ ភ្លាម នោះ មាន ក្មេី ម្នាក់ ជា មាណព ឈ្មោះ សែម លើក សំណួរ មួយ សួរ ទៅ សម្លាញ់ សុខ ថា៖

- បង សុខ ខ្ញុំ មិន សូវ យល់សោះ ថា ហេតុ អ្វី បាន ជា ឯក ឧត្តម សម-រង្សី និង កឹម-សុខាចេះ តែ នាំគ្នា ចូលរួម បោះឆ្នោត ?

ដូច សព្វ ដង សុខ តែងតែ ជា គោល នៃ សំណួរ ព្រោះ គាត់ ជា អ្នក ចេះដឹង ជាង គេ។ ដូច្នេះ គាត់ គ្មាន រញ៉េរា ចិត្ត នឹង ឆ្លើយ នៃ សំនួរ របស់ មិត្ត សែម នោះ ឡើយ។

ចម្លើយ របស់ សុខ៖

- *អ្វី ទៅ ដែល ជា អត្ថរស នៃ លទ្ធិប្រជាធិបតេយ្យ ? គឺ ការ បោះឆ្នោត នេះ ឯង។ បើ សិន ជា គណបក្សសង្គ្រោះ (**គ.ស .ជ**) មិន ចូលរួម ការបោះឆ្នោត តើ យើង អាច ទុក គណ បក្ស នេះ ជា អ្នកប្រជាធិបតេយ្យ បាន ដែរ ឬ ទេ ?*

មាណព សែម បន្ត សំណួរ ថា៖

- *តែ ឯកឧត្តម ទាំង ពីរ តែងតែ ចោទ ជា មុន ថា ការ បោះឆ្នោត ដែល រៀបចំ ដោយ គ.ជ.ប. វា គ្មាន លក្ខណៈ ត្រឹមត្រូវ តាមច្បាប់ ត្រង់ ចំណុច នេះ ឯង ដែល ខ្ញុំ មិន*

*យល់ បើ ការបោះឆ្នោត វា គត ស្របច្បាប់ ចុះ ហេតុអ្វី ក៏ នៅ តែ ចូលរួម បោះឆ្នោត ?*

សុខ គាត់ ដកដង្ហើម មួយៗ សម្លឹង មុខ សម្លាញ់ ហើយ និយាយ ថា៖

- *ប្អូន មិន យល់ ត្រង់ ចំណុច នេះ ជា ចម្ងល់ ត្រឹមត្រូវ មួយ តែ ចំពោះ បង វិញ បង យល់ ថា ការ នេះ វា ជា យុទ្ធសាស្ត្រ នយោបាយ របស់ ឯកឧត្តម ទាំង ពីរ គឺ ទី១ ចង់ ព្រមាន ដល់ គ.ជ.ប. ពី ភាព មិន ឯករាជ្យ របស់ ស្ថាប័ននេះ ទី២ គឺ ចង់ រំឭក ដល់ ប្រជាជនខ្មែរ ពី ភាព តស៊ូ នយោបាយ មួយ រវាង អ្នកប្រជាធិបតេយ្យ និង អ្នកកាន់ អំណាច ផ្តាច់ការ តាម ការបោះឆ្នោត ហេតុនេះឯង ជនជាតិខ្មែរ ដែល ជា អ្នក ស្រឡាញ់ លទ្ធិប្រជាធិបតេយ្យ ត្រូវ នាំ គ្នា ចូល បោះឆ្នោត ដើម្បីបង្កើត ជា កម្លាំងជាតិ ដែល ជា កម្លាំងប្រឆ្នា ប្រឆាំង តាម អំពើ អហិង្សា នឹង កម្លាំង បាយ របស់ អំណាចផ្តាច់ការ ទីបញ្ចប់ គឺ បង្ហាញ សេចក្តីក្លាហាន របស់ គ.ស.ជ. ថា គេ មិន រញ៉េរា នៅ ចំពោះមុខ ល្បិច ទាំងឡាយ របស់ គណបក្សកាន់អំណាច (**គ.ប.ជ**) ទោះ បី ដឹង ជា មុន ថា ការបោះឆ្នោត នេះ ជា អាការៈ ក្រៅបញ្ឆោត (simulacre) យ៉ាង ណា ក៏ ដោយ ក៏ ពុំ មែន ជា ឧបសគ្គ សំរាប់ គ.ស.ជ. ដើរ ទៅ រក ជ័យជំនះ បាន នោះឡើយ។*

មាណព សែម ហាក់ បី ដូច ជា មាន អារម្មណ៍ រំភើព ខ្លាំង ណាស់ នូវ ចម្លើយ របស់ សុខ។ គាត់ ញញឹម ប្រកប ដោយ ជំនឿ ថា យុទ្ធសាស្ត្រ លោក  សម-រង្ស៊ី និង កឹម-សុខា ជា  យុទ្ធសាស្ត្រ មួយ ប្រកប ដោយ ប្រសិទ្ធិភាព ជា សេចក្តី សង្ឃឹម សំរាប់ ប្រជាពលរដ្ឋខ្មែរ ដែល កំពុង រងគ្រោះ ពី សំណាក់ អំណាចផ្តាច់ការ។ តែ ពេល នោះ មាន ក្លើ ម្នាក់ ទៀត ឈ្មោះ សាយ មាន ប្រតិកម្ម ហើយ សួរ ទៅ សៅ ជា ក្លៅ ថា៖

- *ក្មួយ សុខ និយាយ ក្បោះក្បាយ ល្អ ណាស់ ដូច សព្វដង ញ ពេលណា គួរ ឲ ចង់ ស្តាប់ តែ ខ្ញុំ ចង់ សួរ យោបល់ ដល់ ក្មួយ សៅ ម្តង ថា តើ វិភាគ របស់ ក្មួយ សុខ អាច ចាត់ ទុក ជា ចម្លើយ ដែល ជាតិខ្មែរ ត្រូវការ ដែរ ឬទេ ?*

សៅ មាន អារម្មណ៍ ទើសទាល់ នូវ សំណួរ នេះ តែ ដូចសព្វដង គាត់ មិន ដែល គេចវេះ មិន ឆ្លើយ នោះឡើយ។ គាត់ ខំប្រឹង បន្តិច ក្នុង គតិ គាត់ ហើយ ឆ្លើយ ថា៖

- *ក្លើ សុខ លើក លក្ខណៈ មួយ សំខាន់ ណាស់ យក មក ធ្វើ ជា ហេតុផល ក្នុង ការចូលរួម បោះឆ្នោត របស់ គណបក្សសង្គ្រោះជាតិ គឺ ទុក ការបោះឆ្នោត ជា អត្តរស់ របស់ លទ្ធិប្រជាធិបតេយ្យ។ ចំពោះ ខ្ញុំ ហេតុផលនេះ វា គ្មាន អ្វី ដែល អាច យក មក ធ្វើ ជា ជំទាស់ គំនិត បាន នោះ ឡើយ ព្រោះ វា ជា ការពិត មួយ តែ យើង ដឹង ថា ការបោះឆ្នោត មិនមែន ជា អត្តរស់ តែ មួយ គត់ របស់ លទ្ធិប្រជា*

*ធិបតេយ្យ នោះឡើយ។ អត្ថរស់ ជា ច្រើន ទៀត ដូច យ៉ាង សេរីភាព, សមភាព និង នីតិរដ្ឋ ក៏ សុទ្ធ ជា គ្រឹះ សំខាន់ នៃ លទ្ធិប្រជាធិបតេយ្យ ដែរ។ តែ ខ្ញុំ ជឿ ច្បាស់ ថា សុខ ឯង ក៏ បាន ដឹង វា ច្បាស់ ហើយ។ បញ្ហា ធំ ដែល ចោទ ជា សំណួរ បើ ខ្ញុំ តាម ស្តាប់ ការវិភាគ របស់ សុខ គឺ គេ អាច សួរ ថា តើ យើង អាច យក* ***អកុសល (le mal)*** *ជា មធ្យោបាយ ព្រោះ ដោយ ខ្វះ មធ្យោបាយ ឯទៀត មក ធ្វើ ជា អាវុធ ប្រឆាំង នឹង អកុសល បាន ដែរ ឬទេ ? សំណួរ នេះ ជា សំណួរ បិត នៅ លើ សីលធម៌ ជា បឋម តែ បើ សុខ ឯង យល់ ឃើញ ថា គេ អាច យក អកុសល មក ធ្វើ ជា* ***កុសល (le bien)*** *ក្នុង ការ រក ដំណោះ ស្រាយ បញ្ហា ជាតិ បច្ចុប្បន្ន បាន ក្នុង គំនិត នេះ វា មាន ទំហំ វា ធំធេង ណាស់ ព្រោះ វា ជា ប្រធានសិក្សា មួយ ដែល នាំ បង្កើត ជា ទំនាស់ គំនិត មិន ចេះចប់។ ដូច អ្នកឈ្នះ គេ តែងតែ លើក មក ធ្វើ ជា ហេតុផល ថា៖ "ជ័យជំនះ នៅ ទី បញ្ចប់ ជា ការបញ្ជាក់ ថា មធ្យោបាយ ដែល យក មក ប្រើ គឺ វា ពិត ជា ត្រឹមត្រូវ"។ នៅ ក្នុង ទស្សនៈ នេះ វា មាន សទិសភាព (ressemblance) នឹង ហេតុផល នៃ លទ្ធផល នៃ ការបោះឆ្នោត ថ្ងៃ ទី ២៨ កក្កដា ឆ្នាំ ២០១៣ ដែល គ.ស.ជ. អាច ចាត់ ទុក ជា លទ្ធផល វិជ្ជមាន ព្រោះ វា អាច បង្ហាញ ជា ភស្តុតាង បាន ថា ជម្រើស ចូលរួម បោះឆ្នោត ជា ជម្រើស ត្រឹមត្រូវ ព្រោះ វា មាន ជ័យជំនះ ភាយ ចេញ ជាក់ស្តែង ពី ការបោះឆ្នោត*

*នេះ ដែល គេ អាច យក វា មក ធ្វើ សម្ភារកម្ម (matérialiser) នូវ អប្រជាប្រិយភាព របស់ គណបក្សកាន់ អំណាច បាន។*

សុខ មាន ប្រតិកម្ម ចំពោះ ការវិភាគ របស់ សៅ ជា មិត្ត ហើយ ឆ្លើយ កាត់ ភ្លាម ថា៖

- *ខ្ញុំ មិន ដែល និយាយ ថា គ.ស.ជ. យក អកុសល មក ធ្វើ ជា កុសល ជា មធ្យោបាយ នោះឡើយ ហើយ នៅ ក្នុង ចំណុច នេះ ខ្ញុំ មិន ដឹង ថា តើ សៅឯង មើល ឃើញ បែប ណា ថា មាន អកុសល នៅ ក្នុង ទង្វើ របស់ គ .ស.ជ. ក្នុង ការចូលរួម បោះឆ្នោត ?។*

សៅ បិត នៅ ស្ងៀម មួយ ភ្លែត ក្រោយ បន្តិច មក ក៏ ឆ្លើយ តប នឹង ក្លើ ថា៖

- *ដូច ខ្ញុំ រំឭក ប្រាប់ សំឡាញ់ ទាំងអស់ នៅ ទីនេះ ជា មុន ថា យើង កំពុង នាំ គ្នា ពិចារណា អំពី កុសល និង អកុសល ក្នុង ជម្រើស ចូលរួម បោះឆ្នោត ហើយ ជា ប្រធានសិក្សា មួយ មាន ទំហំ ធំ ទូលាយ ណាស់ ព្រោះ វា បិត ក្នុង ភូមិ សិលធម៌។ សុខ ឯង និយាយ ថា តើ ខ្ញុំ មើល ឃើញ បែប ណា ថា មាន អកុសល ក្នុង ជម្រើស នៃ ការ ចូលរួម បោះឆ្នោត របស់ គ.ស.ជ.។ ចំណុច នេះ សុខ ឯង ដឹង ច្បាស់ហើយ ថា អកុសល នេះ វា មាន ធាតុ ជា សជាតិក (inné) នៅ ក្នុង ជម្រើស ណា មួយ ដែល យើង ជ្រើស*

*យក វា មក អនុវត្ត ព្រោះ ក្នុង ជម្រើស និមួយៗ យើង តែងតែ លើក កុសល និង អកុសល មក ថ្លឹង ជា និច្ច មុន នឹង សម្រេច។ ហេតុនេះឯងហើយ ដែល ខ្ញុំ លើកយក អកុសល មក ពិចារណា ក្នុង ទង្វើ របស់ គ.ស.ជ.។ សុខ ឯង មិន អាច និយាយ ថា ក្នុង ជម្រើស នៃ ការចូលរួម បោះឆ្នោត របស់ គ.ស.ជ. អ្នកដឹកនាំ គណបក្ស តត បាន ពិភាក្សា ជា មុន ថ្លឹង ដើម្បី រក សមតា (équilibre) រវាង កុសល និង អកុសល នោះឡើយ ដូចយ៉ាង ក្នុង វិភាគ របស់ សុខ ឯង ខ្លួន លើក ទិដ្ឋភាព នៃ កុសល ច្រើន ណាស់ មក ធ្វើ ជា ហេតុផល នៃ ជម្រើស របស់ គ.ស.ជ. តែ ខ្លួន តត បាន លើក ទិដ្ឋភាព នៃ អកុសល មក ថ្លឹង បង្ហាញ ដល់ ក្លើ យើង នៅ ទី នេះ អោយ បាន ដឹង ផង។ តែ ថ្វី បើ គ្មាន ទស្សនៈ ផ្ទុយ ក៏ ដោយ ក៏ ខ្ញុំ មិន ជំទាស់ ដាច់ខាត់ នោះដែរ។ ប៉ុន្តែ ដូច ខ្ញុំ បាន និយាយ អម្បាញ់មិញ នេះ ថា ក្នុង ជម្រើស និមួយៗ វា តែងតែ មាន ទិដ្ឋភាព ផ្ទុយ របស់វា ដែល មាន ធាតុ ជា សជាតិក គឺ អកុសល នោះ ឯង ហើយ នៅ ក្នុង ចំណុច នេះ ដែល ក្លើយើង នៅ ទី នេះ ចង់ ដឹង យល់ បើ ខ្ញុំ មិន ប្រឡំ។*

ក្នុង ពេល នោះ អ្នក ចូលរួម ក្នុង ការសំណេះ សំណាល សំដែង បញ្ជាក់ ពីចំណង់ ចង់ដឹងយល់ របស់ គេ អំពីទិដ្ឋភាព អកុសល

នេះ។ ក្រោយ បន្តិច ពី ការសំដែង ទឹកចិត្ត នេះមក សុខ និយាយ ឡើង ថា៖

- *ពិត ដូច្នេះ មែនហើយ តែ សៅ ឯង យកពាក្យអកុសល មក ប្រើ ហាក់ បី ដូច ជា ខ្លាំង បន្តិចព្រោះ ថា វា គ្មាន បន្តិច សោះ នៅ ក្នុង អារម្មណ៍ របស់ គណបក្សសង្គ្រោះជាតិ។ អ្វី ដែល គេ កំពុង ធ្វើ គឺ ក្នុងគោលបំណង រក ប្រយោជន៍ ជូន ប្រទេស ជាតិ តែប៉ុណ្ណោះ។*

សៅ កម្រើក ខ្លួន បន្តិច លើ កៅអី ដែល ខ្លួន កំពុង អង្គុយ ហើយ ឆ្លើយ តប ទៅ នឹង ក្លើ សុខ ថា៖

- *អកុសល វា អាច កើត មាន បាន គ្រប់ ឱកាស ទាំង អស់ ក្នុង គំនិត មាន បំណង ក្តី ឥត បំណង ក្តី ហើយ ការ យក ពាក្យ អកុសល មក ប្រើ វា គ្មាន ការទង្គិច អ្វី នឹង សីលធម៌ ដែល អាច ចាត់ ទុក ថា ជា ការបំផ្លើស នោះ ដែរ ព្រោះទី១ ពាក្យ នេះ ជា ពាក្យ ផ្ទុយជម្លួតា នឹង ពាក្យ កុសល ទី២ វា ជា ការឆ្លើយ មួយ ស្របនឹង បរិការណ៍ នៃ នយោបាយ នៅ ក្នុង ស្រុក នា បច្ចុប្បន្ន នេះ ដូចយ៉ាង យក ពាក្យ សង្គ្រោះជាតិ មក ធ្វើ ជា គោលដៅ នោះដែរ។ លោក សម-រង្ស៊ី និង កឹម-សុខា សុខចិត្ត ចូល រួមគ្នាព្រោះ យល់ ឃើញ ថា ស្ថានការណ៍ របស់ជាតិ វា មក ដល់ ដំណាក់ ការ មួយ ដែល តម្រូវ ឲ មាន កម្លាំងជំមួយ សំរាប់ ប្រឆាំង នឹង អំណាចផ្តាច់ការ ដើម្បី សង្គ្រោះជាតិ។ ដូច្នេះ ការ*

រូបរួម នេះ វា អាច អោយ គេ ធ្វើ អនុមាន បាន ថា នៅ ក្នុង ស្រុកខ្មែរ សព្វថ្ងៃ  វា គ្មាន នីតិរដ្ឋ ព្រោះ មាន អំណាច ផ្តាច់ការ ជា របប ដឹកនាំរដ្ឋ។ សុខ ឯង ដឹងដែរ ថា នីតិរដ្ឋ នេះ គេ ទុក វា ជា គ្រឹះ នៃ លទ្ធិប្រជាធិបតេយ្យ។ បើ គ្មាន នីតិរដ្ឋ ចុះ  ហេតុ  ម្តេច ក៏  គណបក្សសង្គ្រោះជាតិ ជ្រើស យក ការចូលរួម បោះឆ្នោត ដែលជា អភិក្រម[3] មួយ ដែល គេ អាច យក វា មកអនុវត្ត បាន នៅ តែ ក្នុង ប្រទេស មួយ ដែល មាន នីតិរដ្ឋ។ ភាព ផ្ទុយគ្នា នេះ ឯង ហើយ ដែល ជា អកុសល ក្នុងចេតនា របស់ អ្នកដឹកនាំ គ.ស.ជ.។ ហើយ ភាព ផ្ទុយគ្នានេះ វា បង្កើត ដោយ ខ្លួន ឯង នូវ ទំនាស់ ជា និច្ច រវាង គោលការណ៏ និង សកម្មភាព ដែល ជា ឧបសគ្គសំខាន់ ដើម្បី ធ្វើ អោយ បាន សម្រេច នូវ គោលបំណង។ ទំនាស់ ជា និច្ច នោះ គឺ ឋិត នៅ លើ ការគោរព នៃ ការបកស្រាយ ច្បាប់ របស់ គណបក្ស កាន់អំណាច អោយ ស្រប តាម តែ ប្រយោជន៏ ដែល គេ ចង់ បាន។ ដូច្នេះ បើ គណបក្ស កាន់ អំណាច គេ អនុញ្ញាត អោយ គណបក្សសង្គ្រោះជាតិ ធ្វើ អ្វី មួយ ទើប គ.ស.ជ. អាច ធ្វើ បាន។ ធ្វើ បែប នេះ យូរៗទៅ នាំ អោយ គេ លែង មើលឃើញ គោលការណ៏ របស់ ខ្លួន ដែល បាន កំរិត ទុក ថា ត្រូវ តែ ដូរ អ្នកដឹកនាំ ដើម្បី សង្គ្រោះជាតិ។ ទំនាស់ បែប នេះ ឯង ដែល នាំ ឲ គ.ស.ជ ដើរ

---

3 អភិក្រមៈ processus។

*វិលវល់ នៅ ក្នុង តែ បញ្ហា ទំនាស់ របស់ខ្លួន ដែល ខ្លួន ជា បង្កើត វា ដោយ ខ្លួនឯង ហើយ លែងដឹង ថា ខ្លួន កំពុង ចង់ ធ្វើ អ្វី ថែម ទៅទៀត។ ភាព វិលចុះ វិលឡើង នេះ វា បង្ហាញ អត្តរស់ របស់ គ.ស.ជ. នៅត្រឹមតែ ជា* ***គណបក្ស សំរាប់ តែ បោះឆ្នោត****។ ទោះ បី ឈ្នះក្តី បើ គណបក្ស កាន់ អំណាច គេ មិន ព្រម ផ្ទេរ អំណាច អោយ ក៏ ខ្លួន គ្មាន លទ្ធភាព ប្រើ ជ័យជំនះ របស់ខ្លួន ដើម្បី យក អំណាច ដែរ ព្រោះ ខ្លួន ធ្វើ សកម្មភាព ក្នុង ក្របខណ្ឌ នៃ អំណាច អ្នកដឹកនាំ នៅ ក្នុង ប្រទេស ឥត នីតិរដ្ឋ។ ដូច យ៉ាង បើ គ្រប់ ស្ថាប័នរដ្ឋ មាន មហាក្សត្រ, ក្រុមព្រឹក្សាធម្មនុញ្ញ , គ.ជ.ប. ថា ខ្លួន ជា អ្នកចាញ់ តើ ខ្លួន មាន អ្វី ទៀត សំរាប់ ជា ឧបាស្រ័យបុនរាព្រឹត្ត*[4] *ព្រោះ ក្នុង ប្រទេស គ្មាន នីតិរដ្ឋ "អ្នកខ្លាំង តែងតែ យល់ត្រូវ ជា និច្ច"។*

សុខ ឆ្លើយ តប វិញ ភ្លាម ថា៖

- *ម្ចាស់ឆ្នោត គេ នាំ គ្នា ធ្វើ បាតុកម្ម ទាមទារ រក យុត្តិធម៌ តើ សៅ ឯង មិនទុកជា ឧបាស្រ័យបុនរាព្រឹត្ត នោះ ឬទេ ?*

សៅ ឆ្លើយ តប ទៅ ក្លើ ជា សម្លាញ់ ថា៖

- *បាតុកម្ម ដើម្បី អ្វី បើ គ្រាន់ តែ ហែ ក្បួនមូតូ ស្រែក សុំ អោយ រក យុត្តិធម៌។ ហើយ ក្នុង ការទាមទារ នោះ ទៀត គេ សួរ ថា សុំ ចំពោះ នរណា ដែល អាច ទុក ជា អ្នក*

---

[4] *ឧបាស្រ័យ បុនរាព្រឹត្ត ; voie de recours*។

*រក យុត្តិធម៌ ? បើ គ្រប់ ស្ថាប័នជាតិ គេ ថា គ.ស.ជ. ជា អ្នកចាញ់ ទៅ ហើយ។ ស្ថានភាព ទ័លច្រក វា នៅ ត្រង់ នាំ គ្នា គោរព ច្បាប់ របស់ អ្នកកាន់អំណាចផ្តាច់ការ។ ការ គោរព នេះ គឺ ដូច ហាមឃាត់ខ្លួន ដោយ ខ្លួនឯង អោយ ខ្លួនឯង ធ្វើ សកម្មភាព ក្នុង ប្រយោជន៍ គណបក្ស កាន់ អំណាច។ ក្នុង ភាពទ័ល នេះឯង ដែល នាំ អោយ គណ បក្សសង្គ្រោះជាតិ គ្មាន ផែនការ អ្វី ទៀត ក្រៅ ពី សុំ គណ បក្ស កាន់អំណាច ធ្វើ ការចរចា តែ ប៉ុណ្ណោះ ហើយ ការ ចរចា នោះទៀត មិន ច្បាស់ ថា ខ្លួន ចង់ បាន អ្វី មួយ ពិត នោះ ទេ គឺ ចរចា ដើម្បី រក្សា សេចក្តីសុខ របស់ អ្នក ដឹកនាំ តែប៉ុណ្ណោះ។ ហើយ ជា ពិសេស ទៅទៀត សព្វថ្ងៃ នេះ លោក សម-រង្ស៊ី និង កឹម-សុខា តត ដឹងគ្នា ទៅវិញ ទៅមក ថា ម្នាក់ៗ កំពុង ធ្វើ អ្វី ចង់ បាន អ្វី នោះ ផង។ នេះឯង ជា អកុសល សំរាប់ ជាតិ នៃ ជម្រើស ដែល ចូល រួម ការបោះឆ្នោត គ្មាន សេរី និង គ្មាន យុត្តិធម៌។*

សុខ ឆ្លើយ តប ថា:

*« រឿង នេះ ជា រឿង អតីតកាល រឿង សំខាន់ គឺ ខ្មែរ អ្នក ស្រឡាញ់ លទ្ធិប្រជាធិបតេយ្យ ត្រូវ នាំ គ្នា រួមគ្នា សង្គ្រោះជា តិ។ បើ សៅ ឯង នៅ តែ លើក រឿង ដែល កន្លង រួច មក ហើយ មក និយាយ បែប នេះ គឺ ខ្មែរ ពុំ អាច រក ដំណោះស្រាយ ឃើញ ទេ ?*

ប្រតិមកម្ម បែប នេះ បញ្ជាក់ អោយ ឃើញ ថា សុខ មិន យល់ ស្រប លើ ការវិភាគ របស់ សម្លាញ់ សៅ នោះឡើយ។ តែ ការ នេះ ជា រឿង ធម្មតាទេ ព្រោះ វា ឋិត នៅ ក្នុង ក្របខណ្ឌ នៃលទ្ធិ ប្រជាធិបតេយ្យ។ ប៉ុន្តែ យើង ដឹង ថា ទំនាស់ គំនិត ឬ វិចារ វិទ្យា តែងតែ បង្កើត ជា និច្ច នូវ គំនិត ថ្មី ទោះ បី វា មិន ទាន់ មានភាព ជា ការព្រមព្រៀង រវាង គ្នាច្រើន (consensus) យ៉ាង ណា ក៏ ដោយ តែ វា អាច បង្កើត ជា ដំណោះស្រាយ កំបាំង មួយ (solution latente) ក្នុង បដិវាទកម្ម។ រសមោចនាកម្ម នេះ (sécrétion) វា មាន នៅ ក្នុង ច្បាប់ធម្មជាតិ។ សៅ មិន ឆ្លើយ តប ទៅ នឹង ប្រតិកម្ម របស់ ក្លើនោះឡើយ ព្រោះ ខ្លួន ដឹង ថា សុខ កំពុង រស់ ក្នុង ឧត្តមគតិនិយម តែ មិន ដឹង ថា វា កើត ចេញ ពី ទោសៈ ឬ ពី ការពិចារណា។ តែ សៅ ដឹង ច្បាស់ ថា នៅ ក្នុង ស្ថានភាព នយោបាយនៅ ស្រុកខ្មែរ សព្វថ្ងៃ នេះ លទ្ធិប្រជាធិបតេយ្យ ត្រូវ បាន គណបក្សកាន់ អំណាច លុប ចោល បាត់ ទៅ ហើយ តែ បើ លោកសម-រង្ស៊ី និង កឹម-សុខា ធ្វើ មិន យល់ ដឹង ហើយ នៅ តែ បន្ត ភាគកម្ម (participation) ដូច យ៉ាង ការចូលរួម បោះឆ្នោត ជា មួយ គណបក្ស កាន់អំណាច ដែល គេ រៀបចំ វា ឡើង ជា អាការៈក្រៅ ញ្ញោត (simulacre) នៃ លទ្ធិប្រជាធិបតេយ្យ គឺ ច្បាស់ ជា ភាគកម្ម នេះ ក្លាយ ទៅ ជា ការជួយ ឧបត្ថម្ភ ដល់ ការបញ្ឈប់ ដំណើរ នៃ ប្រជាធិបតេយ្យូនីយកម្ម នៅ ស្រុកខ្មែរ ជា ពុំខាន៕

**ថ្ងៃទី ២៦ កុម្ភៈ ឆ្នាំ ២០១៧**